**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ</u>

ខ្ញុំបាទឈ្មោះ **ឈីង សុនវ៉ា** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ០១១៣៥៦១៩៥ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៩ តាមរយៈនេះ សូមប្រគល់សិទ្ធិតំណាងដោយអាណត្តិទូទៅ និងដោយឥតកែប្រែ ទៅឲ្យអភិបាល និង អ្នកស្នងតំណែងនៃ ក្រុមហ៊ុន **Ming Fai International Holdings Limited** (បូករួមទាំងបុគ្គលជម្រះបញ្ជីដែលត្រូវបានតែងតាំងជំនួសអភិបាលរបស់ក្រុមហ៊ុន **Ming Fai International Holdings Limited**) (តទៅនេះត្រូវហៅកាត់ថា «**អ្នកតំណាង**») ដែលជាក្រុមហ៊ុនដែលបានចុះបញ្ជីក្រោមច្បាប់នៃ Cayman Islands មានអត្តលេខចុះបញ្ជីលេខ ១៨៧៣០២ និងមានអាសយដ្ឋានចុះបញ្ជីនៅ P.O. Box 309, Ugland House, Grand Cayman, KY1-1104, Cayman Islands ក្នុងការគ្រប់គ្រងរាល់សកម្មភាពពាណិជ្ជកម្ម និងរាល់សិទ្ធិរបស់ខ្ញុំដែលមានក្នុងនាមជាម្ចាស់ភាគហ៊ុនម្នាក់របស់ក្រុមហ៊ុន **មីង ហ្វៃ ខូលលីធី អ៊ីមិនលីធីស៍** (**ខេមបូឌា**) **ឯ.ក** ដែលបានចុះបញ្ជីយ៉ាងត្រឹមត្រូវក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រោមលេខចុះបញ្ជីពាណិជ្ជកម្មលេខ ០០០២៩៤៧៥ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៧ និងមានអាសយដ្ឋានចុះបញ្ជីនៅ ផ្លូវជាតិលេខ៤១ (ផ្លូវអង្គខ្លុង) ភូមិវាលវង់ ឃុំសែនដី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ (តទៅនេះត្រូវហៅកាត់ថា «**ក្រុមហ៊ុន**») ដែលមានខ្ញុំបាទជាម្ចាស់ភាគហ៊ុនចំនួន ៣.៨២៥.០០០ (បីលានប្រាំបីសែនពីរម៉ឺនប្រាំពាន់) ភាគហ៊ុន ត្រូវនឹង ៥១ (ហាសិបមួយ) ភាគរយនៃភាគហ៊ុនចុះបញ្ជីសរុបរបស់ក្រុមហ៊ុន។

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះ ផ្តល់ជូន**អ្នកតំណាង** ឬបុគ្គលដែលត្រូវបានចាត់តាំងនិងផ្តល់សិទ្ធិក្នុងការឈរឈ្មោះបោះឆ្នោតក្នុងកិច្ចប្រជុំម្ចាស់ភាគហ៊ុន និងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក្នុងការចាត់ចែងគ្រប់ទិដ្ឋភាពនៃការគ្រប់គ្រង និងប្រតិបត្តិការរបស់ក្រុមហ៊ុន ដោយរួមបញ្ចូលជាអាទិ៍ ការចាត់ចែង ឬការទិញលក់ទ្រព្យសម្បត្តិ ការតែងតាំងអ្នកគ្រប់គ្រង និងនិយោជិត ការសម្រេចចិត្តលើប្រតិបត្តិការប្រចាំថ្ងៃ ការថែរក្សាឯកសារ និងកំណត់បញ្ជី ការប្រកាសនូវប្រាក់ចំណេញ ចុះហត្ថលេខាលើកំណត់ហេតុអង្គប្រជុំ ដាក់ពាក្យសុំនានាជាមួយក្រសួងស្ថាប័នមានសមត្ថកិច្ច និងបញ្ហាផ្សេងទៀតរបស់ក្រុមហ៊ុនដែលអនុញ្ញាតិដោយច្បាប់ជាធរមាន និងតំណាងអោយក្រុមហ៊ុន **Ming Fai Holdings Limited** ហើយជាអ្នកតំណាងរបស់ក្រុមហ៊ុន **Ming Fai Holdings Limited** ក្នុងការប្រមូលភាគលាភឬប្រាក់ចំណេញដែលបានប្រកាសមកអោយខ្ញុំក្នុងនាមជាម្ចាស់ហ៊ុនក្រុមហ៊ុន ដែលនឹងត្រូវផ្ទេរ និង ប្រគល់អោយក្រុមហ៊ុន **Ming Fai Holdings Limited** ស្របតាម ប្រការ ៨.១ នៃ កិច្ចព្រមព្រៀងវិសោធនកម្មលើកិច្ចព្រមព្រៀងម្ចាស់ភាគហ៊ុន (Amendment and Restatement Agreement of Shareholders′ Agreement) ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤ (ដែលត្រូវបានធ្វើវិសោធនកម្មជារឿយៗ)។

**អ្នកតំណាង** ដោយពុំមានលក្ខខណ្ឌតម្រូវ ឬការហាមឃាត់ ត្រូវមានសិទ្ធិក្នុងការតែងតាំងបុគ្គលដទៃទៀតក្នុងការទទួលខុសត្រូវលើលើសិទ្ធិអំណាច និងសមត្ថកិច្ចដែលបានផ្តល់ឲ្យដោយលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះ ក្នុងករណីដែលបុគ្គលទទួលសិទ្ធិមិនទំនេរដោយប្រការណាមួយ។

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះមានសុពលភាព និងអាចអនុវត្តបានសម្រាប់រយៈពេលមួយឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខាខាងក្រោម និងអាចបន្តសុពលភាពដោយស្វ័យប្រវត្តិ។ លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះមានលក្ខណៈផ្តាច់មុខ និងមិនត្រូវបានលុបចោលដោយមូលហេតុណាមួយឡើយ លុះត្រាតែមានការយល់ព្រមជាលាយលក្ខណ៍អក្សរដោយ**អ្នកតំណាង** និងមានការព្រមព្រៀងពីក្រុមហ៊ុនផងដែរ។

លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិនេះ នឹងជំនួសលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិមុនៗដែលត្រូវបានចុះហត្ថលេខាដោយខ្ញុំដែលពាក់ព័ន្ធនឹងសកម្មភាពដូចគ្នានេះ។

ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០២៤

*ធ្វើជាភាសាខ្មែរចំនួន ០៣ ច្បាប់ និងភាសាអង់គ្លេសចំនួន ០៣ ច្បាប់*

**ឈីម សុនវ៉ា**

***យល់ព្រម និងព្រមព្រៀង***
***លើការប្រគល់សិទ្ធិតំណាងដោយអាណត្តិខាងលើ***

*For and on behalf of*
Ming Fai International Holdings Limited
明 輝 國 際 控 股 有 限 公 司

*Authorized Signature(s)*

ក្រុមហ៊ុន **Ming Fai International Holdings Limited**
តំណាងដោយលោក **ឈីម សុនវ៉ា (អភិបាល)**

***យល់ព្រម និងព្រមព្រៀង***
***លើការប្រគល់សិទ្ធិតំណាងដោយអាណត្តិខាងលើ***

MING FAI QUALITY AMENITIES (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

ក្រុមហ៊ុន **មីង ហ្វៃ ខ្វលលីធី អឹមិននីធីស៍ (ខេមបូឌា) ឯ.ក**
តំណាងដោយលោក **ឈីម សុនវ៉ា (ប្រធានក្រុមប្រឹក្សាភិបាល)**

**KINGDOM OF CAMBODIA**
**Nation Religion King**

# POWER OF ATTORNEY AND PROXY

I, the undersigned, **Ching Tsunwah,** holding Cambodian ID Card no. 011356145 dated 13 September 2019, hereby grant a general and irrevocable power of attorney and proxy to the directors and the successors of **Ming Fai International Holdings Limited** (including a liquidator replacing the directors of Ming Fai International Holdings Limited) (the "**Attorneys**"), a company incorporated in the Cayman Islands, registered under company number 187302, having a registered office at P.O. Box 309, Ugland House, Grand Cayman, KY1-1104, Cayman Islands, or its appointees, over all business activities concerning and my right to vote as the ultimate shareholder of **Ming Fai Quality Amenities (Cambodia) Co., Ltd.**, a private limited company incorporated under the laws of Cambodia and registered with the Ministry of Commerce with registration no. 00029475 dated 24 November 2017, having the registered address at National Road No. 41 (Ang Duong Road), Veal Vong Village, Sen Dei Commune, Samraong Tong District, Kampong Speu Province, the Kingdom of Cambodia (herein referred to as the "**Company"**), of which I am the registered shareholder of 3,825,000 (three million eight hundred and twenty five thousand) ordinary shares representing 51% of the equity interests of the Company.

This power of attorney and proxy gives the Attorneys or its appointees the authority and rights to vote as my proxy at any shareholders' meeting and board meeting to deal with all aspects of the management and operations of the Company including, but not limited to, the disposition or acquisition of assets, appointment of officers and employees, day-to-day business decisions, maintenance of records, declaration of profits, signing minutes, filing documents with the relevant companies registry, and other issues concerning the Company which are allowable by laws in force, and, for and on behalf of Ming Fai Holdings Limited and as Ming Fai Holdings Limited's designated person, to collect all dividends or profit declared to me as a shareholder of the Company, which are to be transferred and assigned only to Ming Fai Holdings Limited pursuant to Clause 8.1. of the Amendment and Restatement Agreement of Shareholders' Agreement dated 22 May 2024 (as amended and restated from time to time).

The **Attorneys,** without further condition or restriction, shall have the right to appoint any other person to undertake all of the power of attorney granted herein in the event that **such Attorney** becomes unavailable.

This power of attorney and proxy is valid and effective for one year from the date as set forth below and can be renewed automatically. This power of attorney and proxy is exclusive and irrevocable unless otherwise made in writing, agreed by the **Attorneys**, and endorsed by the Company.

For the avoidance of doubt, this power of attorney and proxy shall replace and supersede all previous power of attorney and proxy executed by me in relation to the matters dealt with herein.

MADE ON THIS **22nd DAY OF MAY 2024**

*Executed in three copies in Khmer and three copies in English*

**Ching Tsunwah**

***Accepted and agreed***
***to the above representation***

*For and on behalf of*
Ming Fai International Holdings Limited
明輝國際控股有限公司

*Authorized Signature(s)*

**Ming Fai International Holdings Limited**
Represented by: **Ching Tsunwah (Director)**

***Agreed and endorsed***
***the above representation***

MING FAI QUALITY AMENITIES (CAMBODIA) CO., LTD.
KINGDOM OF CAMBODIA

**Ming Fai Quality Amenities (Cambodia) Co., Ltd.**
Represented by: **Ching Tsunwah (Chairman)**